កុមាររៀន កុមារចេះ

ក ១ ២៣

# កុកនិងចចក



កុមាររៀនកុមារចេះ ១២៣

## កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា

រឿង ៖ **កុកនិងចចក**
និពន្ធដោយ ៖ **លោក អុន ងួន**
កែសម្រួលដោយ ៖ **អ្នកស្រី ហ៊ុយ ឆេងរតនា**
វិចិត្ររូបភាពដោយ ៖ **អ្នកស្រី ម៉ាន់ ម៉ាឡែន**

សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

Let's Read
www.LetsReadAsia.org
GET IT ON Google Play

ចចកតែងតែទៅរកចំណី
នៅទឹកបឹងនិងដងអូរ។



កុកក៏ទៅរកចំណីនៅទឹកបឹង
និងដងអូរដែរ។



វេលានោះ ចចកទៅរកចំណី
នៅបឹងតូច។ កុកក៏ទៅរកចំណី
នៅបឹងតូចនោះដែរ។



កុកថា «បងចចក! តោះយើងរកចំណីទុក។ យើងនឹងចែកចំណីជាពីរចំណែក»។



ចចកសួរថា «តើយើង
យកចំណីទុកនៅទីណា?»



កុកនឹកថា បើទុកចំណីនៅលើដី ចចកនឹងឆីដែរ។ បើទុកចំណីនៅលើចុងឈើ ចចកពុំអាចឆីទេ។



កុកថា «យើងនឹងយកចំណីទុកនៅ
លើចុងឈើ។ បើយើងទុកនៅលើ
ដី គេនឹងលួចឆី»។



កុកថា «បងទៅរកចំណីមកទុកផង»។

ចចកក៏ដើរទៅរកចំណី។



ចចកពាំចំណីនិងសាច់ ហុចទៅកុក។



កុកពាំចំណីទាំងនោះទៅទុកនៅលើចុងឈើ។



វេលានោះ ចចកដេកឈើនៅលើដី។

កុកកំពុងស៊ីចំណីនៅលើចុងឈើ។



ចចកថា «បងកុក! បែងចែកចំណីជាពីរចំណែកមក»។



កុកថា «ចំណីនិងសាច់នៅតិចតួចទេ។ បងកុំឆីវាអី»។

ចចកដឹងថា កុកចេះលាក់ចំណីទុក។

ចចកក៏ដឹងថា កុកចេះកុហក។





ចចកដេកយំចង់ឆីចំណី។

កុកសុីចំណីផង សើចចំអក

ដាក់ចចកផង។

រំពេចនោះ ...





កុកក៏នៅលើដី។



កុកឈឺជើងទាំងពីរ។



ចចកយកអាសាកុក។



ចចកខំថែទាំកុក។





ពួកគេក៏ចេះចែកចំណីទៅមក។

ពួកគេសើច ពួកគេអរ។



# ពន្យល់ពាក្យ

១. **ឆី** : ស៊ី ញ៉ាំ ហូប ពិសា

២. **ពាំ** : នាំយកអ្វីៗដោយខាំនឹងមាត់

៣. **លាក់** : ធ្វើអ្វីដោយបិទបាំងមិនចង់ឱ្យគេដឹង

៤. **កុហក** : និយាយមិនពិត

៥. **អាសា** : ជួយ



# សំណួរ

១. តើកុកនិងចចកតែងតែទៅរកចំណីនៅឯណា?

២. តើកុកបបួលចចកឱ្យធ្វើអ្វីជាមួយគ្នា?

៣. តើកូនដឹងទេថា ហេតុអ្វីបានជាកុកសើចចំអកដាក់ចចក?

៤. តើកូនធ្លាប់ធ្វើអ្វីដែលមិនល្អដាក់មិត្តភក្តិរបស់កូនដែរឬទេ? ហេតុអ្វី?













IPEA, Kg.Chhnang, 789 copies, SSK, Oct. 2022

បន្ទាប់ពីរៀនចប់មេរៀនទី៦ រំឭក **«ពាក្យប្រកបនឹង ក ក់ ង ង់ ច ច់ ពួក អ និង អ៊ី»** នៃសៀវភៅថ្នាក់ទី២ សិស្សនឹងអាចអានសៀវភៅរឿងនេះបានដោយខ្លួនឯង ដោយពុំចាំបាច់មានអ្នកដទៃជួយឡើយ។

ទោះជាយ៉ាងណា សិស្សថ្នាក់ទី១ ក៏អាចអានសៀវភៅរឿងនេះជាមួយគ្រូបានដែរ ដោយពួកគេអាចមើលនិងរៀបរាប់អំពីរូបភាពនៅក្នុងសៀវភៅរឿងនេះ ហើយអានពាក្យនិងតួអក្សរដែលពួកគេស្គាល់។

សូមចងចាំថា នៅពេលសិស្សចាប់ផ្ដើមអានសៀវភៅកាន់តែឆាប់ គឺកាន់តែប្រសើរសម្រាប់ពួកគេ!



កម្មវិធីជាតិស្ដីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

9 789924 560340
បោះពុម្ពឆ្នាំ២០២២